# ប្រសាសន៍ ឯកឧត្តមបណ្ឌិត Ingo Karsten ឯកអគ្គរដ្ឋទូត នៃ សាធារណរដ្ឋសហព័ន្ធ អាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ ឯកសារ «ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម» នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧

ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ឯកឧត្តម លោកជំទាវ

ភ្ញៀវកិត្តិយស

លោក លោកស្រី ជាទីគោរព!

នេះគឺជាកិត្តិយសដ៏ធំធេងសម្រាប់រូបខ្ញុំផ្ទាល់ដែលត្រូវបានអញ្ជើញឲ្យថ្លែងសុន្ទរកថា នៅក្នុងពិធីជាប្រវត្តិសាស្ត្រមួយនេះ ដែលក្នុងថ្ងៃនេះ ឯកសារ **«ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥»** បានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ខ្ញុំសូមចូលរួមអបអរសាទរ រាជរដ្ឋាភិបាលកម្ពុជា ដែលបានឈានទៅមុខមួយជំហានទៀត នៅក្នុងកំណែទម្រង់ពេញលេញនៃប្រព័ន្ធគាំពារសង្គមដែលមានស្រាប់ ហើយដែលការងារនេះស្ថិតក្រោមការដឹកនាំផ្ទាល់របស់រាជរដ្ឋាភិបាល។  កំណើនសេដ្ឋកិច្ច និងការគាំពារសង្គម គឺជាមូលដ្ឋានគ្រឹះនៃស្ថិរភាពនយោបាយ។ វេលានេះជាវេលាដែលសាកសមសម្រាប់ការងារនេះ ហើយជាការពិតរាជរដ្ឋាភិបាលកម្ពុជាកំពុងសរសេរប្រវត្តិសាស្ត្រថ្មីស្រឡាងមួយ ។

ក្នុងនាមខ្ញុំជាពលរដ្ឋអាល្លឺម៉ង់មួយរូប ខ្ញុំយល់ច្បាស់អំពីអ្វីដែលខ្ញុំកំពុងនិយាយ។ លោក Bismarck ត្រូវបានស្គាល់ថា ជាអ្នកផ្តួចផ្តើមចំបងម្នាក់ក្នុងកិច្ចការនយោបាយប្រទេសអាល្លឺម៉ង់ ចន្លោះឆ្នាំ១៨៦០ ដល់ ឆ្នាំ១៨៩០។ លោកជានាយករដ្ឋមន្ត្រីនៃ រដ្ឋPrussia និងក្រោយមកជា អធិការបតី នៃចក្រភពអាល្លឺម៉ង់ តែលោក Bismarck មិនត្រូវបានគេចងចាំ

ចំពោះអំណាចនយោបាយដែលគាត់មាននាពេលនោះ ហើយដែលបានទាំងផ្លាស់ប្តូរទ្វីបអឺរ៉ុប ប៉ុន្តែគេចងចាំលោក ហើយគាត់មានគុណបំណាច់ ក្នុងប្រទេសអាល្លឺម៉ង់ និងទូទាំងពិភពលោក ក្នុងនាមជាស្ថាបនិក នៃប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមរបស់រដ្ឋអាល្លឺម៉ង់។ ប្រព័ន្ធនេះក្រោយមកបានទទួលការបំពេញបន្ថែមដោយគម្រោង ប្រាក់សោធននិវត្តន៍ និងគម្រោងធានារ៉ាប់រងសម្រាប់អ្នកអត់ការងារធ្វើ ហើយបន្តមក ប្រព័ន្ធនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយពេលដែលកម្មវិធីសុខុមាលភាពសង្គមបានដាក់បញ្ចូល។ ប្រព័ន្ធនេះបានកែប្រែជោគវាសនា និងជីវិតជនជាតិអាល្លឺម៉ង់ទាំងអស់។ ប្រព័ន្ធនេះមានភាពរឹងមាំណាស់ ដែលវាអាចបន្តរស់រានមានជីវិត បើទោះជាបានឆ្លងកាត់សង្គ្រាមលោកពីរដង និងឆ្លងកាត់របបគ្រប់គ្រងប្រទេសផ្សេងៗពីគ្នាជាច្រើនក៏ដោយ។ ហើយពិតណាស់! ប្រព័ន្ធនេះបានឆ្លងកាត់កំណែទម្រង់ និងការកែសម្រួលម្តងហើយម្តងទៀត។ ជាការពិត ពេលខ្លះ ខ្ញុំគិតថា វាគឺជាដំណើរការនៃកំណែទម្រង់ថេរមួយ ហើយវាក៏នឹងត្រូវឆ្លងកាត់ការកែសម្រួលជាថ្មីម្តងទៀតនាពេលអនាគត ក្នុងខណៈពេលដែលសង្គមរបស់ខ្ញុំមានមនុស្សចាស់កាន់តែច្រើនឡើងៗ ហើយជំងឺក៏មានការប្រែប្រួលផងដែរ។

ប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមអាល្លឺម៉ង់ ជាប្រព័ន្ធសំខាន់មួយ បើទោះវាមិនមែនជាសសរសំខាន់បំផុតដែលទ្រសេដ្ឋកិច្ចអាល្លឺម៉ង់ឲ្យរីកលូតលាស់បានយ៉ាងខ្លាំងក្នុងរយៈពេល ៥០ឆ្នាំកន្លងមកនេះក្តី។ ជាថ្មីម្តងទៀត ប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមអាល្លឺម៉ង់ បាននាំអ្នកនយោបាយ អ្នកជំនួញ និងសង្គមស៊ីវិល ឲ្យរួមគ្នាគ្រប់គ្រង តតាំងនឹងវិបត្តិហិរញ្ញវត្ថុពិភពលោកនាឆ្នាំ២០០៨។

រឿងរ៉ាវដំបូងបានចាប់ផ្តើមឡើងក្នុងឆ្នាំ១៨៨៣ ដែលក្នុងឆ្នាំនោះ មានការបង្កើតឡើងនូវច្បាប់ធានារ៉ាប់រងសុខុមាលភាពថ្នាក់ជាតិសម្រាប់ពលករ ហើយត្រង់ចំណុចនេះខ្ញុំសូមបញ្ជាក់ថា ច្បាប់នេះមិនមែនកើតចេញពីការផ្តួចផ្តើមរបស់រដ្ឋមន្ត្រីសុខាភិបាល ឬអ្នកជំនាញផ្នែកសុខាភិបាលនាជំនាន់នោះទេ តែវាជាគំនិតរបស់លោក Bismarck ដែលពេលនោះគាត់ចង់ឈ្នះសម្លេងឆ្នោតរបស់វណ្ណៈពលករដែលកំពុងមានការកើនឡើងខ្លាំង នាពេលបោះឆ្នោតក្នុងឆ្នាំបន្ទាប់។ នៅពេលដែលច្បាប់បានលេចចេញជារូបរាង ហើយមានសមិទ្ធផលល្អៗជាច្រើនកើតឡើងបន្តបន្ទាប់នោះ ប្រព័ន្ធនេះក៏បន្តដំណើរទៅមុខឥតឈប់

ឈរ។ សព្វថ្ងៃនេះ ប្រទេសអាល្លឺម៉ង់មានមោទនភាពនឹងខ្លួនឯង ដែលជាប្រទេសមួយក្នុងពិភពលោកដែលទទួលជោគជ័យក្នុងសេដ្ឋកិច្ចទីផ្សារសង្គម*(សេដ្ឋកិច្ចទីផ្សារសង្គម គឺជាម៉ូដែលសេដ្ឋកិច្ចសង្គមដែលរួមបញ្ចូល ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ជាមួយនឹង គោលនយោបាយសង្គម ដែលប្រព័ន្ធនេះអនុញ្ញាតឲ្យមានការប្រកួតប្រជែងស្មើភាពគ្នានៅក្នុងរង្វង់ទីផ្សារ និងនៅក្នុងសុខុមាលភាពសង្គម។ ពេលខ្លះគេហៅវាថាជាសេដ្ឋកិច្ចទីផ្សារក្លអេដោនេ)*។

ហេតុអ្វីបានជាខ្ញុំលើកឡើងពីប្រវត្តិសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់? ទីមួយ គឺដើម្បីជាការលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យយល់ថា ផលប្រយោជន៍សង្គម ផលប្រយោជន៍សេដ្ឋកិច្ចនយោបាយ និង ផលប្រយោជន៍នយោបាយ គឺធំសម្បើមណាស់។ ទីពីរ គឺដើម្បីបង្ហាញពីភាពអត់ធ្មត់ ព្រោះកិច្ចការនេះមានដំណើរផ្លូវវែងឆ្ងាយណាស់។ ប្រទេសអាល្លឺម៉ង់ទើបតែអាចសម្រេចបាននូវការធានារ៉ាប់រងសុខភាពជាសាកល នាដើមទសវត្សរ៍១៩៦០ គឺ ៧៥ឆ្នាំ ក្រោយពីគម្រោងបានចាប់ផ្ដើម។ ទីបី គឺជាការអញ្ជើញរាជរដ្ឋាភិបាលកម្ពុជាឲ្យរៀនសូត្រពីកំហុស និងបទពិសោធន៍ជោគជ័យដែលពួកយើងបានជួបប្រទះក្នុងកិច្ចការនេះ ហើយដែលនេះជាទុនសម្រាប់រាជរដ្ឋាភិបាលកម្ពុជា យកទៅប្រើប្រាស់ក្នុងការបង្កើតប្រព័ន្ធគាំពារសង្គមរបស់ខ្លួន។ កិច្ចការនេះ មិនត្រឹមតែជាមូលដ្ឋានគ្រឹះដើម្បីសម្រេច គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពប៉ុណ្ណោះទេ តែក៏ជាការបង្កើតមូលដ្ឋានសម្រាប់អនាគតក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ដែលនេះនឹងជំរុញកម្ពុជាឲ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់បាន ត្រឹមឆ្នាំ២០៥០។

ប្រទេសកម្ពុជាមិនមែនកំពុងធ្វើរឿងនេះតែម្នាក់ឯងទេ។ នៅក្នុងតំបន់វិញ សន្ទុះឆ្ពោះទៅរកកំណែទម្រង់សង្គមដែលគាំពារកំណើនសេដ្ឋកិច្ចគឺមានសភាពខ្លាំងក្លា។ កាលពីឆ្នាំ២០១៣ ប្រទេសជាសមាជិកអាស៊ាន បានអនុម័ត សេចក្ដីប្រកាសស្ដីពីការពង្រឹងការគាំពារសង្គម ហើយក្នុងឆ្នាំនេះ ការគាំពារសង្គមត្រូវបានអាស៊ានជ្រើសរើសជាប្រធានបទសម្រាប់ខួប៥០ឆ្នាំនៃសមាគមមួយនេះ។

កម្ពុជា មានកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយចីរភាព ហើយអត្រាកំណើនសេដ្ឋកិច្ចប្រមាណ ៧.៦ភាគរយ ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ ត្រូវបានព្យាករថានឹងនៅតែដើរ

ទៅមុខច្រើនឆ្នាំបន្តទៀត ស្របពេលដែលគោលទស្សនៈសេដ្ឋកិច្ចនៅតែមានភាពវិជ្ជមាន។ កម្ពុជាគួរតែមានមោទនភាពចំពោះសមិទ្ធផលនេះ។ ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន ប្រទេសកម្ពុជា សម្រេចបាននូវសុខសន្តិភាព និងភាពរុងរឿង ហើយបច្ចុប្បន្នជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប។ ទោះជាយ៉ាងនេះក្តី សមិទ្ធផលនយោបាយ សមិទ្ធផលសេដ្ឋកិច្ច និងការអភិវឌ្ឍទៅមុខបន្តទៀត ត្រូវតែមានការទ្រទ្រង់ដោយ គោលនយោបាយគាំពារសង្គម ដែលវានឹងផលិតចេញមកវិញ នូវទំនិញសង្គមសំខាន់ៗ ដូចជា សុខភាព ការអប់រំដែលមានគុណភាព ឱកាសសេដ្ឋកិច្ច និងការរស់នៅប្រកបទៅដោយសេចក្តីថ្លៃថ្នូរ និងមានអាយុវែង។

ពីដំបូង ខ្ញុំបាននាំអ្នកទាំងអស់គ្នាស្វែងយល់បន្តិចពីប្រវត្តិសាស្រ្តអាល្លឺម៉ង់ ហើយជាបន្ទាប់ខ្ញុំសូមលើកឡើងខ្លះៗពីបច្ចុប្បន្នភាពនៃសង្គមនយោបាយប្រទេសអាល្លឺម៉ង់។ ប្រទេសអាល្លឺម៉ង់កំពុងតែត្រៀមខ្លួនរៀបចំការបោះឆ្នោត ដែលនឹងប្រព្រឹត្តទៅ នាខែកញ្ញាខាងមុខនេះ។ ក្នុងខណៈពេលដែល កាសែតអន្តរជាតិ ផ្តោតសំខាន់ច្រើន ទៅលើផែនការកិច្ចការបរទេស របស់គណបក្សដែលចូលរួមប្រកួតប្រជែងនោះក៏ដោយក៏សម្រាប់អ្នកបោះឆ្នោតវិញ វានៅតែជារឿងចាំបាច់ជាងចំពោះពួកគាត់ ត្រង់ចំនុចថា គណបក្សទាំងនោះនឹងធ្វើអ្វីខ្លះ**នៅក្នុង**ប្រទេសអាល្លឺម៉ង់ និង**សម្រាប់**ជនជាតិអាល្លឺម៉ង់ ក៏ដូចជាសម្រាប់អ្នកដែលកំពុងរស់នៅក្នុងប្រទេសអាល្លឺម៉ង់។ ប្រធានបទស្តីពី ការគាំពារសង្គម នៅតែជារបៀបវារៈសំខាន់ដដែល។ ជាឧទាហរណ៍ ប្រជាពលរដ្ឋចាប់អារម្មណ៍ ចង់ដឹង ថាតើការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាព នឹងត្រូវពង្រឹងតាមរបៀបណាខ្លះ ហើយថាតើការចំណាយទៅលើប្រព័ន្ធថែទាំសុខភាព និងសុខុមាលភាពសង្គម នឹងត្រូវបានបែងចែក យ៉ាងដូចម្តេច រវាង អ្នកមានចំណូលខ្ពស់និងអ្នកមានចំណូលទាប រវាង អ្នកមានការងារនិងអ្នកអត់មានការងារ រវាងមនុស្សពេញវ័យនិងមនុស្សចាស់ រវាងប្រជាជនរស់នៅទីក្រុងនិងប្រជាជនរស់នៅតាមទីជនបទ និង រវាងសេដ្ឋកិច្ចរៀបរយនិងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ជាទូទៅ ការគាំពារសង្គមអប្បបរិមាត្រូវបានកំណត់តាមសង្គមជាតិនីមួយៗ ហើយជាការពិត អត្ថប្រយោជន៍ និងការបង្វែរសង្គម ក្នុងប្រទេសកម្ពុជា និងប្រទេសអាល្លឺម៉ង់ យ៉ាងហោចណាស់ក្នុងពេលបច្ចុប្បន្ននេះ មានភាពខុសគ្នា ។ ទោះជាយ៉ាងណាក៏ដោយ បទពិសោធន៍ជុំវិញពិភពលោកបានបង្ហាញថា ការគាំពារសង្គមអប្បបរិមាគឺអាចធ្វើទៅបាន

មិនថាស្ថិតក្នុងដំណាក់កាលណាមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចទេ ប្រសិនបើកិច្ចការនេះ ត្រូវបានធ្វើឡើងក្នុងល្បឿនយឺតល្មមៗ ហើយដែលសម្រាប់សន្តិភាព ស្ថិរភាព និងកំណើនសេដ្ឋកិច្ច។

ប្រសិនបើកម្ពុជា កំពុងស្វែងរក ឬក៏កំពុងរង់ចាំសម្រាប់ពេលវេលាដែលសាកសមក្នុងការដាក់ចេញនូវ គម្រោងគាំពារសង្គមដែលអាច បង្ការភាពខ្វះខាត តាមរយៈ ការគាំពារពិការភាព សោធនសង្គម និង ជំនួយសង្គមសម្រាប់ប្រជាជនក្រីក្រ ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ ហើយ សម្រាប់ទាំងអស់គ្នាដែលត្រូវការគម្រោងនេះ មិនថាក្រុមដែលមានសម្លេងតិចក្នុងសង្គម និងក្រុមងាយរងគ្រោះ ជនជាតិដើមភាគតិច ឬក៏ជនពិការក៏ដោយ ពេលវេលាបានមកដល់ហើយ។ ភាពជោគជ័យ នាពេលអនាគតរបស់គោលនយោបាយគាំពារសង្គមនេះគឺជាស្នាដៃរបស់រាជរដ្ឋាភិបាលឥឡូវនេះ។

ជំហានដំបូងបានអនុម័តប្រកបទៅដោយជោគជ័យរួចមក ហើយដែលក្នុងនោះ៖

- ខ្ញុំសូមអបអរសាទរ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ដែលកាលពីឆ្នាំមុន បានបំពេញបន្ថែម កម្មវិធីធានារ៉ាប់រងឧបទ្ទវហេតុសម្រាប់និយោជិតធ្វើការក្នុងស្ថាប័នរៀបរយ ដោយបញ្ចូលនូវ គម្រោងធានារ៉ាប់រងសុខុមាលភាពសង្គម។ នាដើមឆ្នាំនេះ ប.ស.ស បានដាក់ចេញគម្រោងថ្មីមួយទៀតគឺ គម្រោងធានារ៉ាប់រងសុខុមាលភាពសង្គមថ្មី សម្រាប់និយោតជិតបម្រើការឲ្យស្ថាប័នរដ្ឋ។

- ខ្ញុំក៏សូមអបអរសាទរ រាជរដ្ឋាភិបាលកម្ពុជាដែលបានបង្កើតឲ្យមានមូលនិធិសមធម៌ដើម្បីសុខភាពថ្នាក់ជាតិដែលមូលនិធិនេះគ្របដណ្តប់ការចំណាយសុខភាពទាំងអស់របស់ពលរដ្ឋដែលកាន់ប័ណ្ណសមធម៌ ហើយវាក៏ជួយចំណាយទៅលើមធ្យោបាយធ្វើដំណើរទៅកាន់មណ្ឌលសុខភាពសាធារណៈផងដែរ។

- ទោះជាយ៉ាងនេះក្តី ប្រជាជនកម្ពុជាដែលងាយរងគ្រោះជាងគេខាងផ្នែកហិរញ្ញវត្ថុដោយសារតែបន្ទុកចំណាយទៅលើសុខភាព មិនមែនជាប្រជាជនក្រីក្រទៀតឡើយ។ ផ្ទុយមកវិញគឺ ប្រជាជនដែលមានចំណូលខ្ពស់បន្តិចលើខ្សែបន្ទាត់ក្រីក្រ និងអ្នកធ្វើការ

នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្រុមទាំងនេះមានដល់ទៅជិត៦០%នៃប្រជាជនសរុប។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមថ្មីនេះ បានដាក់របៀបវារៈ ដោយធ្វើយ៉ាងណា ឲ្យក្រុមនេះនឹងត្រូវទទួលបានការគ្របដណ្តប់ក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមដែលអាចធ្វើទៅបាន ដែលនេះវានឹងជួយត្រួសត្រាយផ្លូវដល់កម្ពុជាសម្រេចឲ្យបាន ការធានារ៉ាប់រងសុខភាពជាសាកលត្រឹមឆ្នាំ២០៣០ ដែលវាមានន័យថាប្រជាជនមានលទ្ធភាពទទួលបានការថែទាំសុខភាពដែលមានគុណភាព ដោយមិនចាំបាច់ចំណាយថវិកាផ្ទាល់ខ្លួន។ ការងារនេះនឹងកាត់បន្ថយភាពក្រីក្រ ហើយថែរក្សាប្រជាជនឲ្យមានសុខភាពល្អ និងសកម្មក្នុងកិច្ចការសេដ្ឋកិច្ចនិងនយោបាយ។

ប្រព័ន្ធគាំពារសង្គមថ្មីនេះនឹងៈ

- ផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្ស ដោយបង្កើតឲ្យមានកម្មវិធីផ្ទេរសាច់ប្រាក់ថ្មីមួយសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារ ព្រមតាំងពង្រឹងកម្មវិធីអាហារូបករណ៍តាមសាលារៀន និងកម្មវិធីផ្តល់អាហារដល់សាលារៀន។ ធ្វើរបៀបនេះ ការពរពោះដែលមានហានិភ័យខ្ពស់ និងកង្វះអាហារូបត្ថម្ភ អាចនឹងកាត់បន្ថយ និងបង្ការបានព្រមគ្នា។ នេះគឺជាជំហានដ៏សំខាន់មួយដែលសំដៅទៅលើការការពារក្រុមទាំងពីរ ដែលជាក្រុមងាយរងគ្រោះជាងគេ និងសំដៅទៅលើការធានាអនាគតប្រជាពលរដ្ឋកម្ពុជាជំនាន់ក្រោយ។

- ជួយរៀបចំមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាលក្នុងការចាប់ផ្តើមរៀបចំប្រព័ន្ធវិភាគទានប្រាក់សោធន។ ជាការពិត ភាគច្រើនលើសលុបនៃប្រជាជនកម្ពុជាវ័យចំណាស់ទាំងស្រី ទាំងប្រុស មិនទាន់មានស្ថិរភាពខាងប្រាក់ចំណូល មិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ចូលនិវត្តន៍ ហើយពួកគាត់ត្រូវតែបន្តធ្វើការ ដរាបណាពួកគាត់នៅធ្វើបាន។ ដូច្នេះ វាជារឿងចាំបាច់បំផុតដែលវិសាលភាពនៃប្រព័ន្ធនេះត្រូវគ្របដណ្តប់មិនមែនតែមនុស្សមួយក្រុមតូចទេ ប៉ុន្តែត្រូវពង្រីកទៅកាន់ប្រជាពលរដ្ឋឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

មុននឹងបញ្ចប់ វាជាការប្រសើរដែលមើលឃើញថា ការបង្កើតឡើងនូវ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមនេះ ក៏រាប់បញ្ចូលនូវបទពិសោធន៍របស់ប្រទេសជិតខាងក្នុងអាស៊ាន។ នេះជាចំនុចមួយដែលអនុញ្ញាតឲ្យដៃគូអភិវឌ្ឍន៍ មានឱកាសជួយសម្របសម្រួល។ សុខដុមនីយកម្មនៃប្រព័ន្ធគាំពារសង្គមទូទាំងអាស៊ាន នឹងក្លាយជាប្រធានបទដ៏សំខាន់ ក្នុងខណៈពេលដែលរបៀបវារៈនៃសមាហរណកម្មសេដ្ឋកិច្ចនិងសង្គម ក្នុងអាស៊ានកាន់តែមានភាពចាស់ទុំនាពេលអនាគត។

ប្រទេសអាល្លឺម៉ង់តាមរយៈអ្នកជំនាញខ្លាំងៗមកពីGIZ និងដៃគូអភិវឌ្ឍន៍ ដែលមានវត្តមានក្នុងថ្ងៃនេះរួមមាន USAID, ILO, AFD, JICA, UNICEF និង European Union ត្រៀមខ្លួនរួចជាស្រេចក្នុងការជួយជ្រោមជ្រែងការអនុវត្តកិច្ចការនេះ។ ពួកយើងអាចចូលរួមតាមរយៈការចែករំលែក បទពិសោធន៍ជាក់ស្តែងដែលពាក់ព័ន្ធនឹងប្រធានបទនេះ ហើយនិងតាមរយៈការជួយសម្របសម្រួលកម្ពុជាក្នុងការផ្ទេរនិងទទួលយកចំណេះដឹង ក៏ដូចជាជំនាញ មកពីប្រទេសដទៃ និងជុំវិញតំបន់។ ទោះជាយ៉ាងនេះក្តី វាចាំបាច់ដែលត្រូវសង្កត់ធ្ងន់ថា ប្រទេសកម្ពុជាត្រូវតែបង្កើតប្រព័ន្ធដែលសមស្របទៅនឹងបរិបទដែលខ្លួនត្រូវការ។ បទពិសោធន៍របស់ប្រទេសដទៃទៀត គ្រាន់តែជាវេទិកាសិក្សាដែលឆ្លុះបង្ហាញពីការអនុវត្តល្អៗកន្លងមកនិងចំនុចដែលត្រូវចៀសវាង តែប៉ុណ្ណោះ។

ក្នុងដំណើរផ្លូវទៅមុខទៀត វាមានការងារប្រឈមដែលទន្ទឹមរង់ចាំរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែដំណើរនេះជាដំណើរដ៏មានតម្លៃ។ ការវិនិយោគទុនទៅលើ ការគាំពារសង្គមនឹងលេចចេញជាផ្លែផ្កាវិជ្ជមានជាច្រើនដូចជា៖ សុខភាព ផលិតភាព និង សាមគ្គីភាពក្នុងសង្គម។ ជំហានដំបូងៗ វាពិតជាលំបាកក្រៃលែង ប៉ុន្តែគ្រប់ដំណើរទាំងអស់គឺផ្តើមចេញពីចំនុចនេះ ក៏ប៉ុន្តែដល់ពេលដាក់វាឲ្យចេញជារូបរាងនិងមានចលនា សត្វដំរីពិបាកបញ្ឈប់ណាស់។ ប្រព័ន្ធគាំពារសង្គមថ្នាក់ជាតិដែលមានសកម្មភាពរស់រវើក ដែលអាចនិយាយតាមន័យនយោបាយបានថា ជាសត្វដំរីដ៏ខ្លាំងក្លាមួយក្បាល។ ប្រព័ន្ធនេះនឹងផ្លាស់ប្តូរជីវិតប្រជាជន ហើយអនុញ្ញាតឲ្យប្រជាពលរដ្ឋកម្ពុជារស់នៅបានយ៉ាងសប្បាយរីករាយ និងយូរអង្វែង។

សូម អរគុណ!!!